ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ៧៥៤ អក
ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨
សាលក្រមព្រហ្មទណ្ឌលេខ ០៩៩ "ណ"
ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកណ្តាល**

បានបើកសវនាការជាសាធារណៈនាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ ដែលមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្តាល

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៥៤ អ.ក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ ៖

១. ឈ្មោះ [redacted] ខេមរិទ្ធិ ភេទប្រុស កើតឆ្នាំ១៩៨៦ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកធនាគារម៉ារ៉ូហាន់ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] យឿន (រស់) ម្តាយឈ្មោះ [redacted] បូរី (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

២. ឈ្មោះ [redacted] សុភាព ភេទប្រុស កើតឆ្នាំ១៩៩៥ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ក្រូច (រស់) ម្តាយឈ្មោះ [redacted] លំអង (រស់) ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិវៃ្លលកោះ ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភាព ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទខាងលើមានដូចតទៅ៖**

កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ២០:១៥ នាទីឈ្មោះ [redacted] ខេមរិទ្ធ បានជិះម៉ូតូជូនឈ្មោះ [redacted] បូរី ភេទប្រុស មកឆ្លងទូកដកោះវៃ្លល ស្ថិតក្នុងភូមិកោះវៃ្លល ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ដើម្បីឆ្លងទៅត្រើយខាងលិច ។ ពេលមកដល់កំពង់ឆ្លង ដោយចាំយូរពេកឈ្មោះ [redacted] ខេមរិទ្ធ ក៏បានចុចស៊ីផ្លេ



Scanned with CamScanner

ម៉ូតូខ្លាំងៗ ទើបធ្វើឱ្យម្ចាស់ទូកដឈ្មោះ [redacted] សំបូរ ភេទប្រុស ខឹងបានស្រែកឱ្យឈ្មោះ [redacted] ខេមរិទ្ធ ថាប្រញាប់ងាប់ទៅណា ក៏កើតជាទំនាស់ពាក្យសម្ដីគ្នា ស្របពេលនោះឈ្មោះ [redacted] ក្រូច និងប្រពន្ធឈ្មោះ [redacted] លំអង មកសួរនាំកើតជាទំនាស់ពាក្យសម្ដីជាមួយឈ្មោះ [redacted] ខេមរិទ្ធ ស្រាប់តែឈ្មោះ [redacted] ខេមរិទ្ធ បានចូលទៅធាក់ឈ្មោះ [redacted] ក្រូច ដួលទៅនឹងដីចំការស្ពៃក្បែរនោះ ។ ពេលនោះឈ្មោះ [redacted] លំអង បានចូលទៅប្រតាយប្រតប់គ្នាជាមួយឈ្មោះ [redacted] ខេមរិទ្ធ បណ្ដាលឱ្យដួលទៅលើដើមស្ពៃទាំងអស់គ្នា ឃើញដូច្នេះឈ្មោះ [redacted] សុភាព ត្រូវជាកូនរបស់ឈ្មោះ [redacted] ក្រូច បានរត់ចូលមកយកដំបងវាយទៅលើឈ្មោះ [redacted] ខេមរិទ្ធ ពេលនោះឈ្មោះ [redacted] យឿន ត្រូវជាឪពុករបស់ឈ្មោះ [redacted] ខេមរិទ្ធ បានចូលមកអោបពីលើឈ្មោះ [redacted] ខេមរិទ្ធ កុំឱ្យវាយត្រូវឈ្មោះ [redacted] សុភាព វាយបណ្ដាលឱ្យរបួស ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ០៨០ ដកសស ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ របស់តំណាងអយ្យការសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៦៦៣ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាដំណោះស្រាយលេខ ១៧២៤ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ២០១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល ។

**នាពេលសវនាការ**

១- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] យឿន ភេទប្រុស បានឆ្លើយថា៖ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ កូនរបស់ខ្លួនឈ្មោះ [redacted] ខេមរិទ្ធបានជូនឈ្មោះ [redacted] បូរី ទៅកំពង់ដរ តែដោយសារអង្គុយចាំកូនយូរពេកខ្ញុំក៏ដើរទៅរកកូននៅកំពង់ដរកោះរំដួល លុះដើរជិតទៅដល់ក៏ឃើញកូនខ្លួនដួលទៅលើដី ដោយសារតែឈ្មោះ [redacted] សុភាព និងបក្ខពួករបស់គេមានឈ្មោះ [redacted] ក្រូច ឈ្មោះ [redacted] សំបូរ និងម្នាក់ទៀតមិនស្គាល់ឈ្មោះ បានយកដំបងព្រួតវាយកូនខ្ញុំ ហើយខ្ញុំបានស្រែកឃាត់ ប៉ុន្តែឈ្មោះ [redacted] សុភាព និងបក្ខពួកមិនព្រមស្ដាប់ខ្ញុំទេ ហើយពួកគេនៅតែបន្តវាយកូនរបស់ខ្ញុំ ឃើញដូច្នេះខ្លួនក៏ចូលទៅទ្រាបខ្លួនពីលើកូន ហើយត្រូវពួកគេវាយមកលើខ្ញុំ ។

២- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សំបូរ បានឆ្លើយថា៖ កាលពីថ្ងៃ កើតហេតុវេលាម៉ោងប្រាំបីយប់នាទី ឈ្មោះ [redacted] ខេមរិទ្ធ បានចុចស៊ីផ្លេហៅខ្ញុំឱ្យមកចម្លង ប៉ុន្តែខ្លួនពុំបានទៅចម្លងគាត់ភ្លាមនោះទេ ដោយសារខ្លួននៅចាំម៉ូយឆ្លងសិន ពេលខ្ញុំបានម៉ូយហើយ ក៏ឆ្លងទូកដរទៅត្រើយខាងកើត នៅពេលទៅដល់ច្រាំងស្រាប់តែឈ្មោះ [redacted] ខេមរិទ្ធ បានជេរ និងរកវាយខ្លួន ប៉ុន្តែបានឈ្មោះ ស្មី ដែលកំពុងជិះទូកដរជួយឃាត់ និងបានមិត្តភក្តិរបស់ឈ្មោះ [redacted] ខេមរិទ្ធ ចូលមកជួយឃាត់ឈ្មោះ [redacted] ខេមរិទ្ធ យកទៅផ្ទះ ប៉ុន្តែមិនទាន់បានទៅដល់ផ្ទះផងឈ្មោះ [redacted] ខេមរិទ្ធ បានឃើញឈ្មោះ [redacted] ក្រូច ដែលត្រូវជាបងថ្លៃខ្លួនដើរមក ក៏ស្ទុះធាក់ឈ្មោះ [redacted] ក្រូច ដួលទៅក្នុងគុម្ពស្ពៃ ភ្លាមនោះឈ្មោះ [redacted] លំអង ដែលត្រូវជាបងស្រីបង្កើតរបស់ខ្លួនបានស្ទុះចូលមកទៅលើកប្ដី ស្រាប់តែឈ្មោះ [redacted] ខេមរិទ្ធបានចាប់បោចសក់ និងធាក់ចំកបងស្រីរបស់ខ្លួន ។

៣- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] លំអង បានឆ្លើយថា៖ កាលពីថ្ងៃកើតហេតុ ខ្លួនកំពុងនៅផ្ទះស្រាប់តែឮឈ្មោះ [redacted] ខេមរិទ្ធ ស្រែកជេរប្អូនរបស់ខ្លួនឈ្មោះ [redacted] សំបូរ ឮដូចនេះខ្លួន និងប្ដីខ្លួនក៏ដើរទៅមើលស្រាប់តែឈ្មោះ [redacted] ខេមរិទ្ធ ស្ទុះមកធាក់ប្ដីរបស់ខ្ញុំ ឃើញដូចនេះខ្លួនក៏ស្ទុះទៅលើកប្ដី ស្រាប់តែឈ្មោះ

[redacted] ខេមរិទ្ធ ចាប់បោចសក់ និងធាក់ចំក និងមុខរបស់ខ្លួន លុះបានបន្តិច ប្អូនរបស់ខ្លួនឈ្មោះ [redacted] សំបូរ និងកូនរបស់ខ្ញុំ [redacted] សុភាព ចូលមកឃាត់ ។

៤- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ក្រូច បានឆ្លើយថា៖ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល ៨យប់ ខ្ញុំនៅផ្ទះដែលនៅជិតកំពង់ដចម្ងាយប្រហែល ៨០ម៉ែត្រ ក៏បានឮសម្លេងមានគេស្រែកឡូឡា ក៏ដើរទៅមើលជាមួយប្រពន្ធឈ្មោះ [redacted] លំអង ។ ពេលទៅដល់ឃើញឈ្មោះ [redacted] ខេមរិទ្ធ កំពុងស្រែកជេ ម្រាយប្អូនថ្លៃជាម្ចាស់ទូកដឈ្មោះ [redacted] សំបូរ និងរកវាយប្អូនថ្លៃខ្លួន ។ ពេលឈ្មោះ [redacted] ខេមរិទ្ធ កំពុងវាយប្អូនថ្លៃ ស្រាប់តែងាកមើលក្រោយឃើញខ្លួន ក៏ត្រឡប់មកក្រោយវិញ រួចធាក់ខ្លួនចំដើមទ្រូងមួយជើង ធ្វើឱ្យខ្ញុំផ្ងារក្រោយចុលគុម្ពក្បែរនោះ ។ ពេលនោះប្រពន្ធខ្លួន បានស្ទុះមកជួយលើកខ្លួន ស្រាប់តែឈ្មោះ [redacted] ខេមរិទ្ធ ស្ទុះចាប់បោចសក់ក្បាលផ្តួលគុម្ពស្អំ ហើយយកដៃទាំងពីរទាញសក់ យកជើងទល់បំពង់កជាប់ ឃើញដូចនេះប្អូនថ្លៃឈ្មោះ [redacted] សំបូរ និងកូនប្រុសឈ្មោះ [redacted] សុភាព បាននាំគ្នាជួយចាប់ទាញដៃឈ្មោះ [redacted] ខេមរិទ្ធ ចេញទើបឈ្មោះ [redacted] ខេមរិទ្ធ ត្រូវបានឈ្មោះ [redacted] យឿន បានមកទាញចាប់ឈ្មោះ [redacted] ខេមរិទ្ធ ចេញ ប៉ុន្តែឈ្មោះ [redacted] ខេមរិទ្ធ នៅតែស្ទុះមកវាយខ្លួន និងប្រពន្ធ ខ្លួនបន្តទៀត រហូតឈ្មោះ [redacted] យឿន ចាប់ក្រៀកជាប់ ។ ពេលឈ្លោះគ្នា ខ្លួន និងឈ្មោះ [redacted] ខេមរិទ្ធ មិនមានកាន់ដំបងក្នុងដៃទេ ។

៥- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បូរី បានឆ្លើយថា៖ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រាំបីយប់ ឈ្មោះ [redacted] សំបូរ បានចុះពីលើទូកដរដោយមានកាន់ដំបងជ្រុងប្រវែងប្រហែលកន្លះម៉ែត្រដើរសំដៅទៅឈ្មោះ [redacted] ខេមរិទ្ធ ហើយឈ្មោះ [redacted] សំបូរ បានស្រែកថា "អញវៃអាហ្នឹងឱ្យងាប់" ឃើញដូចនេះខ្លួនក៏ចូលទៅឃាត់ ស្រាប់តែឈ្មោះ [redacted] សុភាព បានកាន់ដំបងរាងមូលប្រហែលមួយម៉ែត្រ និងបក្ខពួកព្រួតវាយទៅលើឈ្មោះ [redacted] ខេមរិទ្ធ ។ នៅពេលនោះឈ្មោះ [redacted] យឿន ដែលត្រូវជាឪពុកបានចូលឃាត់ និងទ្រោបទៅលើខ្លួនឈ្មោះ [redacted] ខេមរិទ្ធ មិនឱ្យវាយ ប៉ុន្តែឈ្មោះ [redacted] សុភាព និងបក្ខពួកនៅតែបន្តការវាយ ។

៦- សាក្សីឈ្មោះ [redacted] សុខម៉េង បានឆ្លើយថា៖ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រាំបីយប់ ខ្លួននៅផ្ទះស្រាប់តែឮឈ្មោះ [redacted] ខេមរិទ្ធ ស្រែកជេរប្តីរបស់ខ្ញុំ ។ ខ្ញុំក៏ដើរទៅកំពង់ចម្លង ស្រាប់តែឃើញឈ្មោះ [redacted] ខេមរិទ្ធ ស្រែកជេរនឹងប្រុងហាក់ធាក់ប្តីរបស់ខ្ញុំ តែបានឈ្មោះ ស្មី ជួយឃាត់ ។ ស្រប់ពេលនោះបងថ្លៃរបស់ខ្ញុំឈ្មោះ [redacted] លំអង និងប្តីរបស់គាត់ឈ្មោះ [redacted] ក្រូច និងឪពុករបស់ឈ្មោះ [redacted] ខេមរិទ្ធ មកដល់ខណៈពេលឈ្មោះ [redacted] ក្រូច ដើរជិតមកឈ្មោះ [redacted] ខេមរិទ្ធ បានស្ទុះហាក់ធាក់ឈ្មោះ [redacted] ក្រូច បណ្តាលឱ្យដួលក្នុងគុម្ពស្អំ ពេលនោះឈ្មោះ [redacted] លំអង បានចូលជួយទៅលើប្តី ក៏ត្រូវបានឈ្មោះ [redacted] ខេមរិទ្ធ ចាប់បោចសក់បណ្តាលឱ្យដួលចូលទៅក្នុងគុម្ពស្អំទាំងបីនាក់ ។

៧- សាក្សីឈ្មោះ [redacted] សុខាវុធ បានឆ្លើយថា៖ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រាំបីយប់ ឈ្មោះ [redacted] សុភ័ណ្ឌ បានជិះម៉ូតូមកដល់ផ្ទះខ្លួន ហើយប្រាប់ថា "អ៊ុំទៅជួយមានគេវៃអ៊ុំខ្ញុំងាប់ហើយ" ពេលឮដូច្នេះខ្លួនក៏ជិះម៉ូតូទៅកំពង់ចម្លងកោះរំដួលក៏ឃើញឈ្មោះ [redacted] ខេមរិទ្ធ នៅឈរមុខផ្ទះនឹងអង្រូនផ្ទះព្រមទាំងស្រែកជេរឈ្មោះ [redacted] ក្រូច ហើយខ្លួនឃើញឈ្មោះ [redacted] ខេមរិទ្ធ និងឈ្មោះ [redacted] បូរី ឃាត់ឈ្មោះ [redacted] ខេមរិទ្ធិ កុំឱ្យអង្រូនរបងទៅទៀត ពេលនោះខ្លួនឃើញឈ្មោះ [redacted] ខេមរិទ្ធ របួសត្រង់ភ្នែក ប៉ុន្តែមិនដឹងត្រូវភ្នែកខាងណាទេ ។

៨- សាក្សីឈ្មោះ [redacted] សោភ័ណ្ឌ បានឆ្លើយថា៖ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រាំបីយប់ ឈ្មោះ [redacted] ខេមរិទ្ធ បានជេរមកលើឪពុកខ្លួន ស្របពេលនោះឈ្មោះ [redacted] ក្រូច ឈ្មោះ [redacted] លំអង និងឈ្មោះ [redacted] យឿន បានដើរមកស្រាប់តែឈ្មោះ [redacted] ខេមរិទ្ធិបានជេរទៅលើឈ្មោះ [redacted] លំអង និងបានស្ទុះ

ហាក់ធាក់ឈ្មោះ [redacted] ក្រូច ដួលក្នុងគុម្ពស្ពៃ ឃើញដូច្នេះឈ្មោះ [redacted] លំអង ដែលត្រូវជាប្រពន្ធ បានស្ទុះទៅលើកប្ដី ស្រាប់តែឈ្មោះ [redacted] ខេមរិទ្ធ បានចាប់បោចសក់ឈ្មោះ [redacted] លំអង ដួលចូលគុម្ពស្ពៃទាំងអស់គ្នា ។

៩- សាក្សីឈ្មោះ [redacted] គឹមហ៊ាន់ បានឆ្លើយថា៖ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រាំបីយប់ ខ្ញុំបានឃើញឈ្មោះ [redacted] សុភាព និងបក្ខពួកកំពុងវាយទៅលើឪពុក និងបងប្រុសរបស់ខ្ញុំ ។ ខ្ញុំឃើញបងប្រុសរបស់ខ្ញុំឈ្មោះ [redacted] ខេមរិទ្ធ បែកភ្នែកខាងស្ដាំ និងមានស្លាកស្នាមពេញខ្លួន រីឯឪពុករបស់ខ្លួនឃើញមានស្នាមត្រូវខ្នង ។

១០-ជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ បានឆ្លើយថា៖ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រាំបីយប់ ខ្ញុំបានជិះម៉ូតូជូនឈ្មោះ [redacted] បូរី ទៅឆ្លងដរនៅត្រើយខាងកើត ទៅត្រើយខាងលិចវិញនៅត្រង់ចំណុចកំពង់ចំលងកោះរំដួល ។ លុះចាំប្រហែលមួយសន្ទុះមិនឃើញទូកដរមកចម្លង ខ្ញុំក៏ចុចស៊ីផ្លេដើម្បីផ្ដល់សញ្ញាទៅម្ចាស់ទូកដរ ស្រាប់តែឈ្មោះ [redacted] សំបូរ ដែលជាម្ចាស់ទូកបានស្រែកពីទិសខាងលិចថា "ហ្វែងប្រញាប់ងាប់ទៅណា" ពេលនោះឈ្មោះ សំ បូរី បានដើរមកនិយាយជាមួយខ្ញុំថា "ទូកដរស្រុកបងឯងកាច់ម្លេះ" ខ្ញុំក៏ឆ្លើយថា ប្រហែលជាគាត់ដេរអ្នកផ្សេង ។ បន្តិចក្រោយមកខ្លួននៅមិនឃើញទូកដរមកចម្លង ក៏ចុចស៊ីផ្លេម្ដងទៀត ពេលនោះឈ្មោះ [redacted] សំបូរ ក៏បើកទូកដរមកដល់កំពង់ចម្លង ហើយដើរសំដៅមករកខ្ញុំ ហើយនិយាយថា "វៃអាហ្នឹងឱ្យងាប់" ដោយក្នុងដៃ [redacted] សំបូរ មានកាន់ដំបងឈើប្រវែងកន្លះម៉ែត្រ សំដៅមកវាយខ្ញុំ ប៉ុន្តែបានឈ្មោះ [redacted] បូរី ជួយឃាត់ ស្រាប់តែឈ្មោះ [redacted] សុភាព បានស្ទុះច្រានខ្ញុំដួល ហើយខ្ញុំក៏ក្រោកឡើង និងច្រានឈ្មោះ ក្រូច សុភាព វិញ តែឈ្មោះ ក្រូច សុភាព មិនបានដួលទេ ស្រាប់តែឈ្មោះ [redacted] លំអង បានយកដៃច្របាច់កខ្លួន ហើយនិយាយថា "ម៉េចបានជាវាយកូនអញ" ហើយឈ្មោះ [redacted] លំអង បានច្រានខ្លួនដួលទៅក្នុងគុម្ពស្ពៃ ស្រាប់តែឈ្មោះ [redacted] សុភាព និងបក្ខពួក២ទៅ៣នាក់ បានយកដំបងប្រហែលកន្លះម៉ែត្រ មកវាយលើខ្ញុំ និងឪពុករបស់ខ្ញុំឈ្មោះ [redacted] យឿន ស្របពេលនោះឈ្មោះ [redacted] បូរី បានរត់មកជួយឃាត់ និងសុំអង្វរឈ្មោះ [redacted] សុភាព និងបក្ខពួកកុំឱ្យវាយលើខ្លួន និងឪពុក ស្រាប់តែឈ្មោះ [redacted] សុភាព និងបុរសម្នាក់ទៀតស្ទុះចាប់គៀកខ្លួនឱ្យឈរ ហើយឈ្មោះ [redacted] លំអង បានចាប់ទះកំភ្លៀងខ្ញុំ ហើយឈ្មោះ [redacted] សំបូរ និយាយថា "កុំតែយល់មុខឪពុកឯងទេ កុំអីអញវាយឯងឱ្យងាប់ទម្លាក់ទឹកហើយ" លុះមួយសន្ទុះក្រោយមកសមត្ថកិច្ចមកដល់កន្លែងកើតហេតុ ។

១១-ជនត្រូវចោទឈ្មោះ [redacted] សុភាព បានឆ្លើយថា៖ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រាំបីយប់ ខ្ញុំបានឃើញឈ្មោះ [redacted] ខេមរិទ្ធ ស្ទុះមកបណ្ដាលឱ្យដួលនៅគុម្ពស្ពៃ ហើយម្ដាយរបស់ខ្ញុំ ក៏ចូលជួយឃាត់ស្រាប់តែឈ្មោះ [redacted] ខេមរិទ្ធ ចូលមកបោចសក់ម្ដាយរបស់ខ្ញុំឈ្មោះ [redacted] លំអង ។ នៅក្នុងរឿងនេះខ្ញុំមិនបានវាយទៅលើឈ្មោះ [redacted] ខេមរិទ្ធ ទេ គ្រាន់តែចូលជួយឃាត់ប៉ុណ្ណោះ ។

១២-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ តាមចម្លើយរបស់ជនជាប់ចោទ ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ចម្លើយជនរងគ្រោះ ចម្លើយសាក្សី និងរបាយការណ៍សរុប ព្រមទាំងភស្តុតាងនានាបង្ហាញឱ្យឃើញថាជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ និងជនជាប់ចោទឈ្មោះ [redacted] សុភាព ពិតជាបានវាយគ្នាទៅវិញទៅមកប្រាកដមែន ដែលច្បាប់កំណត់អំពើនេះថាជាបទៈ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិកោះរំដួល ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

១៣-សេចក្ដីសន្និដ្ឋានរបស់មេធាវីឈ្មោះ [redacted] សុខជា ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ៖ តាមចម្លើយជនជាប់ចោទ ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ចម្លើយសាក្សី និងភស្តុតាងនានាបង្ហាញឱ្យឃើញថាកូនក្ដីរបស់ខ្លួនឈ្មោះ [redacted] ខេមរិទ្ធ បានវាយទៅលើឈ្មោះ [redacted] ក្រូច ឈ្មោះ [redacted] លំអង និងឈ្មោះ [redacted] សំ

បូរ គឺដើម្បីការពារខ្លួនពីការវាយរបស់ឈ្មោះ [redacted] ក្រូច ឈ្មោះ [redacted] លំអង និងឈ្មោះ [redacted] សំបូរ ប៉ុណ្ណោះ ហេតុដូច្នេះស្នើសុំឱ្យតុលាការលើកលែងការចោទប្រកាន់មកលើកូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] ខេមរិទ្ធ ពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិវ៉ៃលកោះ ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៣ និងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

១៨-សេចក្តីសន្និដ្ឋានរបស់មេធាវីឈ្មោះ [redacted] វិចិត្រ និងមេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភាព៖ តាមរយៈការពិភាក្សាដេញដោល និងការពិនិត្យភស្តុតាងនៅក្នុងសំណុំរឿង ការចោទប្រកាន់ឈ្មោះ [redacted] សុភាព ពីបទ ហិង្សាដោយចេតនា តាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិចំណុចភូមិកោះរំដួល ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៨ គឺមិនត្រឹមត្រូវនោះទេ ដោយហេតុថា ផ្អែកតាមអង្គហេតុ និងភស្តុតាងក្នុងសំណុំរឿង ពុំមានភស្តុតាងដាក់បន្ទុកលើឈ្មោះ [redacted] សុភាព ហើយសកម្មភាព និងអំពើរបស់ឈ្មោះ [redacted] សុភាព គឺជាការការពារខ្លួនដោយស្របច្បាប់ ហើយបើតាមស្មារតីមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" ហេតុនេះក្នុងនាមជាមេធាវីការពារសិទ្ធិស្នើសុំឱ្យតុលាការ មេត្តាពិនិត្យពិចារណា សម្រេចចេញសាលក្រមចុងក្រោយដោយប្រកាសឱ្យជនជាប់ចោទឈ្មោះ [redacted] ក្រូច រួចខ្លួនពីបទចោទ "ហិង្សាដោយចេតនា" ដោយក្តីអនុគ្រោះ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់ចម្លើយសាក្សី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភាព
-ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

**ក/ អំពីពិរុទ្ធភាព**

១- តាមដីកាដំណោះស្រាយលេខ ១៧២៤ ដកសស ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ (អត្តសញ្ញាណខាងលើ) និងជនជាប់ចោទឈ្មោះ [redacted] សុភាព (អត្តសញ្ញាណខាងលើ) ជាប់ចោទពីបទ: ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិវ៉ៃលកោះ ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

២- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យឿន បង្ហាញឱ្យឃើញថា៖ នៅពេលដែលខ្លួនកំពុងតែទ្រោបខ្លួនពីលើកូនឈ្មោះ [redacted] ខេមរិទ្ធ ក៏ត្រូវបានឈ្មោះ [redacted] សុភាព វាយមកលើខ្លួន ។

៣- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សំបូរ បង្ហាញឱ្យឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ ពិតជាបានវាយទៅលើឈ្មោះ [redacted] ក្រូច ដែលត្រូវជាបងថ្លៃរបស់ខ្លួន ប្រាកដមែន ។

៤- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លំអង បង្ហាញឱ្យឃើញថា៖ ខ្លួនពិតជាត្រូវបានជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ ចាប់បោចសក់ ធាក់ចំក និងមុខរបស់ខ្លួន ប្រាកដមែន ។

៥- តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ក្រូច បង្ហាញឱ្យឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ ពិតជាបានវាយទៅលើប្អូនថ្លៃរបស់ខ្លួនឈ្មោះ [redacted] សំបូរ និងបានធាក់ខ្លួនចំដើមទ្រូងមួយជើង ដួលចូលគុម្ពស្ពំ ប្រាកដមែន ។

៦- តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បូរី បង្ហាញឱ្យឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] សុភាព ពិតជាបានវាយទៅលើ ជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ និងបានវាយទៅលើឈ្មោះ [redacted] យឿន ក្នុងពេលដែលឈ្មោះ [redacted] យឿន ធ្វើការទ្រោបខ្លួនទៅលើជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ ប្រាកដមែន ។

៧- តាមចម្លើយសាក្សីឈ្មោះ [redacted] សុខម៉េង បង្ហាញឱ្យឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ ពិតជាបានធាក់ឈ្មោះ [redacted] ក្រូច បណ្តាលឱ្យដួលចូលគុម្ពស្ពំ និងបានចាប់បោចសក់ឈ្មោះ [redacted] លំអង បណ្តាលឱ្យដួលចូលគុម្ពស្ពំ ប្រាកដមែន ។

៨- តាមចម្លើយសាក្សីឈ្មោះ [redacted] សោភ័ណ្ឌ បង្ហាញឱ្យឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធិ ពិតជាបានធាក់ឈ្មោះ [redacted] ក្រូច ដួលចូលក្នុងគុម្ពស្ពំ និងបានចាប់បោចសក់ឈ្មោះ [redacted] លំអង ចូលក្នុងគុម្ពស្ពំ ប្រាកដមែន ។

៩- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ បង្ហាញឱ្យឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ បានធ្វើការបដិសេធថាខ្លួនមិនបានវាយទៅលើឈ្មោះ [redacted] ក្រូច ឈ្មោះ [redacted] សំបូរ និងឈ្មោះ [redacted] លំអង ទេ ដែលការបដិសេធរបស់ជនជាប់ចោទនេះ គឺបដិសេធដើម្បីឱ្យតុលការធ្វើការលើកលែងការចោទប្រកាន់មកលើខ្លួនតែប៉ុណ្ណោះ ដោយពុំមានភស្តុតាងណាមួយបញ្ជាក់បានថា ខ្លួនពិតជាមិនបានវាយទៅលើឈ្មោះ [redacted] ក្រូច ឈ្មោះ [redacted] សំបូរ និងឈ្មោះ [redacted] លំអង ទេ ។

១០- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុភាព បង្ហាញឱ្យឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] សុភាព បានធ្វើការបដិសេធថាខ្លួនមិនបានវាយទៅលើឈ្មោះ [redacted] ខេមរិទ្ធ ទេ គឺដើម្បីទទួលបានការលើកលែងការចោទប្រកាន់តែប៉ុណ្ណោះ ដោយពុំមានភស្តុតាងណាមួយអាចបញ្ជាក់បានថា ខ្លួនពិតជាមិនបានវាយទៅលើឈ្មោះ [redacted] ខេមរិទ្ធ ទេ ។

១១-តាមរបាយការណ៍សរុបលេខ ០៨៥ របក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ របស់អធិការដ្ឋាននគរបាលស្រុកស្អាង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ ពិតជាបានបង្កអំពើហិង្សាជាមួយឈ្មោះ [redacted] ក្រូច ឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] លំអង នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រាំបី នៅចំណុចភូមិកោះរំដួល ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ។

១២-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយរបស់ជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយជនរងគ្រោះ ចម្លើយសាក្សី និងរបាយការណ៍សរុប ព្រមទាំងភស្តុតាងនានាបង្ហាញឱ្យឃើញថាជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ ពិតជាបានវាយទៅលើឈ្មោះ [redacted] ក្រូច ឈ្មោះ [redacted] សំបូរ និងឈ្មោះ [redacted] លំអង ចំណែកឯជនជាប់ចោទឈ្មោះ [redacted] សុភាព ពិតជាបានវាយទៅលើជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ ប្រាកដមែន ដែលច្បាប់កំណត់អំពើនេះថាជាបទៈ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិកោះរំដួល ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

១៣-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីឈ្មោះ [redacted] សុខជា ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ បង្ហាញឱ្យឃើញថា លោកមេធាវី [redacted] បានស្នើសុំឱ្យតុលាការធ្វើការលើកលែងការចោទប្រកាន់កូនក្តីរបស់ខ្លួនពីបទ ហិង្សាដោយចេតនា ដោយលើកឡើងអំពីការពារខ្លួនពីការវាយរបស់ឈ្មោះ [redacted] ក្រូច ឈ្មោះ [redacted] សំបូរ និងឈ្មោះ [redacted] លំអង ថាជាការការពារខ្លួនដោយស្របច្បាប់ ។ ប៉ុន្តែតាមចម្លើយជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយសាក្សី និងភស្តុតាងនានា បង្ហាញឱ្យឃើញថាជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ បានធ្វើការធាក់ទៅលើដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ក្រូច និងបានប្រតាយប្រតប់គ្នាជាមួយ

ឈ្មោះ [redacted] លំអង ក្នុងរយៈពេលផ្សេងគ្នា នាំឱ្យបទល្មើស និងការឈ្លានពានពុំត្រូវបានកើតឡើងក្នុងពេលជាមួយគ្នានោះទេ ។ គប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ តាមកំណត់ច្បាប់ ។

១៤-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីឈ្មោះ [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភាព បង្ហាញឱ្យឃើញថា លោកមេធាវី [redacted] បានស្នើសុំឱ្យតុលាការធ្វើការលើកលែងការចោទប្រកាន់កូនក្តីរបស់ខ្លួនត្រូវជាជនជាប់ចោទឈ្មោះ [redacted] សុភាព ដោយបានលើកឡើងអំពី ភស្តុតាងមិនគ្រប់គ្រាន់ក្នុងការដាក់បន្ទុកមកលើកូនក្តីរបស់ខ្លួន និងបានលើកឡើងអំពីការការពារខ្លួនដោយស្របច្បាប់ ។ ប៉ុន្តែបើតាមចម្លើយជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយសាក្សី របាយការណ៍មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងនានា បង្ហាញឱ្យឃើញថា ពេលជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ កំពុងតែត្រូវបានឈ្មោះ [redacted] យឿន កំពុងតែអោបចេញ ក៏ជនជាប់ចោទឈ្មោះ [redacted] សុភាព ធ្វើការវាយមកលើជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ ប្រាកដមែន ។ ដោយយោងតាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយជនជាប់ចោទ របាយការណ៍មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងនានា មានបន្ទុកគ្រប់គ្រាន់ក្នុងការចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] សុភាព ពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិវំដួលកោះ ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ ។ គប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុភាព តាមកំណត់ច្បាប់ ។

១៥-តាមរបាយការណ៍របស់នគរបាលយុត្តិធម៌ ចម្លើយជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយសាក្សី ព្រមទាំងភស្តុតាងនានា មានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យឃើញថា កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រហែលប្រាំបីយប់ ឈ្មោះ [redacted] ខេមរិទ្ធ បានធ្វើការចាក់ និងវាយទៅលើឈ្មោះ [redacted] ក្រូច ដែលត្រូវជាឪពុករបស់ឈ្មោះ [redacted] សុភាព បណ្តាលឱ្យដួលទៅនឹងចំការស្ពៃ ឃើញដូច្នេះក៏ជនជាប់ចោទឈ្មោះ [redacted] សុភាព បានវាយទៅលើជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ វិញ រហូតដល់ឈ្មោះ [redacted] យឿន ត្រូវជាឪពុករបស់ឈ្មោះ [redacted] ខេមរិទ្ធ បានចាប់កូនរបស់ខ្លួនចេញកុំឱ្យវាយគ្នាទៀត ប៉ុន្តែពេលឈ្មោះ [redacted] យឿន កំពុងតែចាប់ទាញឈ្មោះ [redacted] ខេមរិទ្ធ ក៏ឈ្មោះ [redacted] សុភាព រត់ទៅវាយឈ្មោះ [redacted] ខេមរិទ្ធ បន្តទៀត ប្រាកដមែន ស្របនឹងការសន្និដ្ឋានរបស់តំណាងអយ្យការ ។

១៦-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ និងជនជាប់ចោទឈ្មោះ [redacted] សុភាព បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់សង្គម ។

១៧-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ និងជនជាប់ចោទឈ្មោះ [redacted] សុភាព ដែលបានប្រព្រឹត្តមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

១៨-មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ និងជនជាប់ចោទឈ្មោះ [redacted] សុភាព ពីបទៈ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិកោះវំដួល ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។ គប្បីតុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ និងជនជាប់ចោទឈ្មោះ [redacted] សុភាព តាមកំណត់ច្បាប់ ។

**ខ/ អំពីសំណង និងជម្ងឺចិត្ត**

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខេមរិទ្ធ ប្តឹងទាមទារសំណងជំងឺចិត្ត និងថ្លៃព្យាបាលរបួសចំនួន ១០,០០០ (មួយម៉ឺន) ដុល្លាអាមេរិក ពីជនជាប់ចោទឈ្មោះ [redacted] សុភាព ។ គប្បីតុលាការសម្រេចទៅតាមព្យសនកម្មដែលបានកើតឡើង ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លំអង ប្តឹងទាមទារសំណងជំងឺចិត្ត និងថ្លៃព្យាបាលរបួស ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លាអាមេរិក ពីជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ ។ គប្បីតុលាការសម្រេចទៅតាមព្យសនកម្មដែលបានកើតឡើង ។

**ហេតុដូច្នេះសម្រេច**

១- ផ្តន្ទាទោសលើជនជាប់ចោទ៖

១.១- ឈ្មោះ [redacted] ខេមរិទ្ធ (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ តែទោសនេះត្រូវអនុវត្តព្យួរ ។

១.២- ឈ្មោះ [redacted] សុភាព (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ តែទោសនេះត្រូវអនុវត្តព្យួរ និងពិន័យជាប្រាក់ចំនួន ២,០០០,០០០ (ពីរលាន) រៀល ។

ពីបទៈ ហិង្សាដោយចេតនា ដែលប្រព្រឹត្តនៅភូមិកោះរំដួល ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

២- បង្គាប់ឱ្យជនជាប់ចោទ៖

២.១ ឈ្មោះ [redacted] ខេមរិទ្ធ សងសំណងជំងឺចិត្ត និងថ្លៃព្យាបាលរបួសទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លំអង ជាទឹកប្រាក់ចំនួន ២,០០០,០០០ (ពីរលាន) រៀល ការទាមទារលើសពីនេះត្រូវច្រានចោល ។

២.២ ឈ្មោះ [redacted] សុភាព សងសំណងជំងឺចិត្ត និងថ្លៃព្យាបាលរបួសទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យឿន ជាទឹកប្រាក់ចំនួន ៤,០០០,០០០ (បួនលាន) រៀល ការទាមទារលើសពីនេះត្រូវច្រានចោល ។

សាលក្រមជំនុំជម្រះនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ខេមរិទ្ធ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យឿន តែកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុភាព កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លំអង និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សំបូរ ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជម្រះ**

[redacted]

បានឃើញ

០៤ កក្កដា ២០២១

តំណាងអយ្យការ

[redacted]

**ព្រះរាជអាជ្ញារង**

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃទី.០៤...ខែកក្កដា ឆ្នាំ ២០២១

**ក្រឡាបញ្ជី**

[redacted]